22. ព្រះអម្ចាស់អើយ សូមប្រទានកម្លាំង
និងផ្គត់ផ្គង់ដល់ក្រុមគ្រួសារនៃសមាជិកក្រុមការងារនៅKabyle
ដែលបានរងការខូចខាតផ្ទះដោយគ្រោះធម្មជាតិ ហើយការពារពួកគេ
នៅពេលពួកគេប្រឈមមុខនឹងការបៀតបៀតក្នុងសហគមន៍ ដោយសារ
សេចក្តីជំនឿរបស់ពួកគេ។ (ទំនុកដំកើង ៩១:១៥)

23. ព្រះវរបិតាសួគ៌ ទូលបង្គំសូមឱ្យក្រុមគ្រួសារនៅអាស៊ីកណ្តាល
ក្នុងករណីជាច្រើន ប្តីប្រពន្ធ និងកូនរបស់ស្ត្រីដែលជឿរួចហើយ
សូមមករកចំណេះដឹងអំពីការសង្គ្រោះនៃព្រះយេស៊ូវគ្រីស្ទ។
(កិច្ចការ ១៦:៣១)

24. ព្រះអម្ចាស់អើយ លួងលោម
និងលើកទឹកចិត្តស្ត្រីអាស៊ីកណ្តាលដែលមានប្តីមិនស្មោះត្រង់
និងគ្មានការទទួលខុសត្រូវ។ ផ្តល់កម្លាំងដល់ស្ត្រីដើម្បីរៀបការ
ជាមួយស្វាមីជាគ្រិស្តសាសនិក ទោះជាមានសម្ពាធពីគ្រួសារក៏
ដោយ។ (រ៉ូម ១២:១២)

25. ក្រុមការងារនៅKabyle
សូមសរសើរតម្កើងដល់ព្រះនាមរបស់ព្រះអង្គ
ចំពោះការលើកទឹកចិត្តដែលពួកគេទទួលបានពីអ្នកស្តាប់
ដែលភាគច្រើនពួកគេមានបានទាក់ទងជាមួយអ្នកជឿផ្សេងទៀតឡើយ។
(ទំនុកតម្កើង ៩៩:៥)

26. ព្រះអម្ចាស់អើយ យើងអធិស្ឋានសម្រាប់ស្ត្រីនៃអាស៊ីភាគកណ្តាល
ដែលទទួលរងពីការគាបសង្កត់ ការបៀតបៀន និងសម្ពាធពីសង្គម
សូមប្រទានកម្លាំងពួកគេឱ្យស៊ូទ្រាំជាមួយនឹងបញ្ហាទាំងនោះ។
(និក្ខមនំ ១៥:២)

27. ព្រះអង្គអើយ សូមប្រទានកម្លាំង
និងក្តីសង្ឃឹមដល់ស្ត្រីវ័យក្មេងនៅអាស៊ីភាគកណ្តាល
ដែលរស់នៅដូចជាអ្នកបម្រើនៅក្នុងផ្ទះឪពុកម្តាយក្មេករបស់ពួកគេ
ដោយគ្មានសិទ្ធិ ឱកាស
ឬសមត្ថភាពក្នុងការទទួលបានការងារផ្សេងទៀតដែលពួកគេចង់ធ្វើ។
(យេរេមា ២៩:១១)

28. ព្រះវរបិតាដ៏មានព្រះហឫទ័យមេត្តាករុណា
សូមផ្តល់ជម្រកដល់អ្នកជឿនៅអាហ្វ្រិកខាងជើងពីភាពតានតឹងដែលឥត
ឈប់ឈរ
នៅពេលដែលពួកគេស៊ូទ្រាំនឹងការកើនឡើងនៃអរិភាពនៅក្នុងតំបន់
រួមទាំងការស្ដីបន្ទោស និងការបៀតបៀនផ្សេងៗផងដែរ។ (ម៉ាថាយ
៥:១១-១២)

29. ព្រះជាម្ចាស់អើយ
ពួកយើងសូមអធិស្ឋានសុំបញ្ឈប់ការខ្វះខាតស្បៀងអាហារនៅអាហ្វ្រិកខា
ងជើង។ ប្រទានដល់អស់អ្នកដែលត្រូវការនិងផ្តល់ប្រាជ្ញាដល់អ្នកដែល
មានមុខតំណែងក្នុងការដោះស្រាយស្ថានភាពនៅទីនោះផងដែរ។
(ទំនុកដំកើង ១៤៦:៧)

30. ព្រះជាអម្ចាស់អើយ
សូមប្រទានកម្លាំងដល់ស្ត្រីដែលបានក្លាយជាគ្រីស្តបរិស័ទនៅអាស៊ីភាគ
កណ្តាល
ប៉ុន្តែមិនអាចសារភាពសេចក្តីជំនឿរបស់ពួកគេដោយបើកចំហរបាន
ដោយសារតែការសារភាពអាចធ្វើអោយពួកគេប្រថុយនឹងការជិះជាន់ពី
សាច់ញាតិរបស់ពួកគេ។ (ទំនុកតម្កើង ៩១:២)

31. ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ
យើងខ្ញុំសូមសរសើរព្រះនាមទ្រង់ ដែលរដ្ឋាភិ
បាលបានបន្ធូរបន្ថយការរឹតបន្តឹងនៃជំងឺកូវីត១៩ធ្ងន់ធ្ងរនៅក្នុងតំបន់ខ្លះៗ
នៃអាហ្វ្រិកខាងជើង។ (ទំនុកតម្កើង ៧១:១៤)

후원안내

국민은행 851-01-0003-724 북방선교방송

최초 입금 후 사무실로 연락 주시기 바랍니다

# Women of Hope

## Prayer Calendar

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង
100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 65,000នាក់



2022. 10.

## ការអធិស្ឋានសម្រាប់ស្ត្រីនៅអាស៊ីភាគកណ្តាល មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង

នៅពេលដែលមនុស្សធ្លាក់ក្នុងស្ថានភាពដ៏លំបាក ពួក
គេនឹងអស់សង្ឃឹម។ ពួកគេត្រូវការជំនួយពីអ្នកដទៃ
ដើម្បីស្វែងរកក្តីសង្ឃឹមរបស់ពួកគេត្រឡប់មកវិញ។
ព្រះជាម្ចាស់ពិតជាចង់ប្រើយើងតាមរបៀបបែបនោះ។
យើងអធិស្ឋានថាស្ត្រីមូស្លីមនឹងដឹងពីអត្តសញ្ញាណពិត
ប្រាកដរបស់ពួកគេនៅក្នុងព្រះ
ហើយផ្លាស់ប្តូរជីវិតរបស់ពួកគេ
នឹងនាំមកនូវការផ្លាស់ប្តូរដ៏អស្ចារ្យនៅក្នុងសហគមន៍។

TWR Korea 북방선교방송

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 phkorea@twrk.or.kr

**អធិស្ឋានសំរាប់……………**

1. យើងសូមសរសើរតម្កើងទ្រង់ ព្រះជាម្ចាស់អើយ
ដែលការចាក់ផ្សាយរបស់ស្ត្រីនៃក្តីសង្ឃឹមនៅអាហ្រ្វិកខាងជើងបានបន្តទៅមុខទៀត ទោះបីជាមានការប្រឆាំងពីមេដឹកនាំនៃសាសនាភាគច្រើនក៏ដោយ។ (១ថែស្សាឡូនិច ៥:១៦-១៨)

2. បិតាអើយ
យើងសូមអធិស្ឋានសុំឲ្យមានការរួបរួមនៃគ្រួសារអាស៊ីភាគកណ្តាល ក្នុងកំឡុងពេលដែលប្តីរបស់ពួកគេទៅក្រៅប្រទេសដើម្បីរកលុយ ហើយត្រូវទុកប្រពន្ធកូនឱ្យនៅម្នាក់ឯង (ទំនុកដំកើង ១៣៣:១)

3. ព្រះវរបិតាអើយ
សូមទ្រង់អនុញ្ញាតឱ្យស្ត្រីគ្រីស្ទាននៃអាស៊ីភាគកណ្តាលមានភាពរឹងមាំខាងព្រលឹងវិញ្ញាណ ដើម្បីអោយពួកគេអាចធ្វើជាទីបន្ទាល់អំពីទ្រង់ក្នុងគ្រួសារ និងមិត្តភក្តិរបស់ពួកគេដែលមិនទាន់ទទួលបានក្តីសង្រ្គោះ។ (កិច្ចការ 1:8)

4. ព្រះអម្ចាស់អើយ សូមការពារក្រុមរបស់យើងនៅKabyle គ្រីស្តបរិស័ទផ្សេងទៀត និងអ្នកដែលមានទំនាក់ទំនងជាមួយជនបរទេស នៅពេលដែលពួកគេជួបប្រទះនឹងភាពអរិភាពកាន់តែខ្លាំងឡើងពីអាជ្ញាធរនៅអាហ្រ្វិកខាងជើង។ (ទំនុកដំកើង ៩១:១)

5. ព្រះវបិតាអើយ សូមអនុញ្ញាតឲ្យអ្នកជឿនៅអាស៊ីភាគកណ្តាល បាមប្រមូលផ្តុំនិងជួបជុំគ្នាពីភូមិផ្សេងៗរបស់ពួកគេ ដើម្បីស្វែងយល់បន្ថែមអំពីទ្រង់ និងចេះផ្តល់អោយគ្នាទៅវិញទៅមក។ (ម៉ាថាយ ១៨:២០)

6. ព្រះអម្ចាស់អើយ សូមនាំមកនូវការលួងលោម និងផ្គត់ផ្គង់ដល់កុមារនៅអាស៊ីភាគកណ្តាល ដែលម្តាយរបស់ពួកគេត្រូវចេញទៅរកការងារធ្វើនៅក្រៅប្រទេស ហើយមិនអាចត្រឡប់មកគ្រួសាររបស់ពួកគេវិញបានទេនៅពេលនេះ ដោយសារព្រំដែនប្រទេសត្រូវបានបិទ។ (ចោទិយកថា ៣១:៨)

7. ព្រះវរបិតា សូមប្រទានប្រាជ្ញាដល់ក្រុមរបស់យើងនៅKabyle នៅពេលពួកគេឆ្លើយសំណួរ និងធ្វើអន្តរកម្មជាមួយអ្នកស្តាប់ការផ្សាយរបស់ស្រ្តីក្នុងក្តីសង្ឃឹម។ (អេសាយ៣៣:៦)

8. ព្រះអម្ចាស់អើយ សូមការពារ លួងលោម និងផ្តល់ជម្រកដល់កុមារនៅអាស៊ីភាគកណ្តាល ដែលកំព្រាបន្ទាប់ពីឪពុកម្តាយបានលែងលះ និងត្រូវរៀបការម្តងទៀត។ (ម៉ាថាយ ១៨:១០)

9. ឱព្រះជាម្ចាស់អើយ
ទូលបង្គំអធិស្ឋានសូមឲ្យអ្នកជឿនៅអាស៊ីភាគកណ្តាលអាចរកឃើញកម្លាំងចិត្តនិងក្តីសង្ឃឹមនៅក្នុងទ្រង់ ដោយសារជីវិតរបស់ពួកគេពោរពេញទៅដោយការលំបាក និងភាពតានតឹងជាខ្លាំង។ (ទំនុកដំកើង ២៨:៧)

10. ព្រះវរបិតា សូមផ្តល់ប្រាជ្ញា
និងគំនិតច្នៃប្រឌិតដល់អ្នកសម្របសម្រួលនៅ Kurdish Kurmanji របស់យើង នៅពេលពួកគាត់ធ្វើការស្រាវជ្រាវ និងសរសេរអត្ថបទសម្រាប់កម្មវិធីស្រ្តីក្នុងក្តីសង្ឃឹម។(និក្ខមនំ ៣៥:៣៥)

**Phum Roung Chak, Sangkat Kok Kleang,**
**Khan Sen Sok, Phnom Penh**
**ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខ័ណ្ឌសែនសុខរាជធានីភ្នំពេញ )**
**Tel: 092 60 60 51 /086 60 60 56**

11. ព្រះអម្ចាស់អើយ
សូមអោយឪពុកម្តាយនៅអាស៊ីភាគកណ្តាលទទួលយកព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់ពួកគេ ហើយដាក់គ្រឹះនៃសេចក្តីជំនឿរបស់ពួកគេនៅលើទ្រង់នៅក្នុងជីវិតរបស់កូនពួកគេ។ (សុភាសិត ២២:៦)

12. ព្រះអង្គអើយ
សូមផ្លាស់ប្តូរដួងចិត្តរបស់អ្នកដែលមានអំណាចក្នុងការផ្លាស់ប្តូរវប្បធម៌នៅអាស៊ីភាគកណ្តាល ជួយ និងប្រទានកម្លាំងដល់ស្រ្តីនៅទីនោះ ដែលស្ថិតនៅក្រោមការរឹតបន្តឹងដ៏ធ្ងន់ធ្ងរបែបនោះផងដែរ។ (២កូរិនថូស ៣:១៧)

13. ព្រះអម្ចាស់អើយ ពួកយើងសូមចូលរួមតាមរយៈសេចក្តីអធិស្ឋាន ជាមួយក្រុមការងារអាហ្វ្រិកខាងជើងរបស់យើង ក្នុងការសរសើរតម្កើងព្រះអង្គ និងចំពោះអស់អ្នកដែលបានលះបង់ជីវិតរបស់ពួកគេដោយសារដំណឹងល្អរបស់ទ្រង់ក្នុងឆ្នាំកន្លងមក។ (ទំនុកដំកើង ៩:១)

14. ព្រះវរបិតាអើយ សូមទ្រង់កម្សាន្តចិត្ត សម្រាលទុក្ខ និងផ្តល់ការងារដល់ស្រ្តី និងម្តាយនៅអាស៊ីភាគកណ្តាល ដែលត្រូវបានទុកចោលអោយនៅតែម្នាក់ឯង ដោយសារអត្រាលែងលះខ្ពស់។ (ភីលីព ៤:១៩)

15. ឱព្រះវរបិតាអើយ
ទូលបង្គំអធិស្ឋានសូមឲ្យស្ត្រីនៅអាស៊ីភាគកណ្តាលទទួលយកសេចក្តីពិតរបស់ព្រះអង្គ ដែលនាំមកនូវសេរីភាពដល់ជីវិតរបស់ពួកគេ។ សូមជួយពួកគេឱ្យមើលឃើញតម្លៃរបស់ពួកគេតាមរយៈព្រះនេត្ររបស់ទ្រង់។ (អេភេសូរ ២:១០)

16. ព្រះអម្ចាស់អើយ
យើងអធិស្ឋានសម្រាប់សុខភាពនៃក្រុមការងារនៅអាហ្វ្រិកខាងជើងរបស់យើង។ សូមឲ្យពួកគេមានវិធីគ្រប់គ្រងជីវិតគ្រួសារ និងបម្រើព័ន្ធកិច្ចរបស់ពួកគេតាមរបៀបដែលទ្រង់សព្វព្រះទ័យ។ (និក្ខមនំ ២៣:២៥)

17. ឱព្រះវរបិតាអើយ យើងអធិស្ឋានថា
ស្រ្តីនៅអាស៊ីភាគកណ្តាលនឹងបដិសេធគំនិតដែលចង់ធ្វើអត្តឃាត នៅពេលដែលភាពតានតឹងបានគ្របសង្កត់ពួកគេ ហើយថ្វាយរាល់ទាំងបញ្ហាពួកគេទៅកាន់ទ្រង់ជំនួសវិញ។ (២កូរិនថូស ១០:៥)

18. ព្រះវរបិតាអើយ សូមទ្រង់ដោះលែងក្រុមគ្រួសារនៅអាស៊ីភាគកណ្តាល ដែលសមាជិកទទួលរងនូវការញៀនស្រា សូមឲ្យពួកគេបានស្វែងរកសេរីភាពដែលមាននៅក្នុងទ្រង់។ (យ៉ាកុប ៥:១៦)

19. យើងសូមសរសើរតម្កើងព្រះនាមទ្រង់
សម្រាប់ក្រុមការងារនៅអាហ្វ្រិកខាងជើង ដែលអាចជួយស្រ្តីនៅKabyleបានក្នុងស្ថានភាពលំបាកដូចជាការរំលោភបំពាន ការលែងលះ និងប្រឈមមុខជាមួយកង្វះអាហារ។ (ទំនុកតម្កើង ៤៦:១)

20. ឱព្រះអម្ចាស់អើយ
ការលែងលះគឺជារឿងធម្មតាណាស់នៅអាស៊ីភាគកណ្តាល។ សូមទ្រង់ផ្សះផ្សាទំនាក់ទំនងពួកគេរវាងគ្នានិងគ្នា និងពួកគេជាមួយទ្រង់ផងដែរ។ (អេភេសូរ ៤:៣២)

21. ឱ ព្រះវរបិតាអើយ
សូមជួយកុមារីកំព្រាដែលងាយរងគ្រោះនៅអាស៊ីភាគកណ្តាល ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយព្រះវិហារក្នុងតំបន់របស់ពួកគេ ដែលអាចអោយពួកគេស្តាប់ឮពីសេចក្តីពិតអំពីទ្រង់ និងអាចដឹកនាំក្នុងជីវិតរបស់ពួកគេផងដែរ។ (យ៉ាកុប ១:២៧)